ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពី

# ការអនុម័តយល់ព្រមលើ
# កិច្ចព្រមព្រៀងសហប្រតិបត្តិការ
# រវាងព្រះរាជាណាចក្រកម្ពុជា
# និងសហគមន៍អឺរ៉ុប

នស/រកម/០៥៩៩/០២

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍អឺរ៉ុប ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រម
# លើកិច្ចព្រមព្រៀង សហប្រតិបត្តិការ
# រវាងព្រះរាជាណាចក្រកម្ពុជា
# និងសហគមន៍អឺរ៉ុប

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍អឺរ៉ុប ដែលធ្វើនៅទីក្រុង លុចហ្សមបួរ ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា ៣.-

ច្បាប់នេះត្រូវបានប្រកាសទុកជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ហត្ថលេខា

ហោ ណាំហុង

លេខ : ១០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ១៩៩៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# កិច្ចព្រមព្រៀងសហប្រតិបត្តិការ

# រវាង

# ព្រះរាជាណាចក្រកម្ពុជា និងសហគមន៍អឺរ៉ុប

## កិច្ចព្រមព្រៀងសហប្រតិបត្តិការ
## រវាងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍អឺរ៉ុប

- រាជរដ្ឋាភិបាលកម្ពុជា គឺជាភាគីម្ខាង
- ក្រុមប្រឹក្សាសហគមន៍អឺរ៉ុប គឺជាភាគីម្ខាងទៀត

ពីពេលនេះតទៅ ត្រូវបានកំណត់រួមគ្នាថា " ភាគី "

ដោយពិនិត្យឃើញយ៉ាងពេញចិត្ត នូវកំណើននៃការផ្លាស់ប្តូរសេដ្ឋកិច្ច និងការពង្រឹងកិច្ចសហប្រតិបត្តិការ រវាង : ម្ខាងគឺសហគមន៍អឺរ៉ុប ដែល ពីនេះតទៅ ត្រូវបានកំណត់ថា " សហគមន៍ " និងម្ខាងទៀត គឺ ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានកំណត់ថា " កម្ពុជា "

ដោយទទួលស្គាល់ទំនាក់ទំនង និងចំណងមិត្តភាពនិងសហប្រតិបត្តិការល្អប្រសើរ រវាងសហគមន៍និង កម្ពុជា

ដោយអះអាងសារជាថ្មី អំពីសារៈសំខាន់នៃការពង្រឹងកិច្ចទំនាក់ទំនងរវាងសហគមន៍ និងកម្ពុជា

ដោយទទួលស្គាល់នូវសារៈសំខាន់ ដែលភាគីទាំងពីរបានផ្តោតទៅលើគោលការណ៍ទាំងឡាយនៃធម្មនុញ្ញ សហប្រជាជាតិ សេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស សេចក្តីប្រកាសនៅទីក្រុងវីយែន និងកម្មវិធី សកម្មភាពរបស់សន្និសិទ្ធពិភពលោក ស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៩៣ សេចក្តីប្រកាសនៅទីក្រុងកូប៉ិនហាហ្គ ស្តីអំពីវឌ្ឍភាពនិងកិច្ចអភិវឌ្ឍន៍សង្គម ព្រមទាំងកម្មវិធី សកម្មភាព ហើយនឹងសេចក្តីប្រកាស នៅទីក្រុងប៉េកាំង ឆ្នាំ១៩៩៥ ព្រមទាំងកម្មវិធីសកម្មភាពរបស់សន្និសិទ្ធពិភពលោកលើក ទី ៤ស្តីពីស្ត្រី

ដោយអះអាងសារជាថ្មីនូវឆន្ទៈរួមនៃការពង្រឹងនិងពង្រីកទំនាក់ទំនងរវាងភាគីទាំងពីរ នៅក្នុងវិស័យនានា ដែលមានផលប្រយោជន៍ទៅវិញទៅមក ដោយឈរលើមូលដ្ឋានស្មើភាព ភាពគ្មានការរើសអើង និងមានអត្ថ ប្រយោជន៍ទាំងសងខាងនិងទៅវិញទៅមក

ដោយទទួលស្គាល់នូវបំណងប្រាថ្នារបស់ភាគី ក្នុងការបង្កើតល័ក្ខខ័ណ្ឌអនុគ្រោះនានាសំរាប់អភិវឌ្ឍពាណិកម្ម និងវិនិយោគរវាងសហគមន៍និងកម្ពុជា ព្រមទាំងភាពចាំបាច់ដែលភាគីត្រូវប្រកាន់ខ្ជាប់គោលការណ៍ ពាណិជ្ជកម្មអន្តរជាតិ ដើម្បីពង្រីកសេរីភាវូបនិយកម្មពាណិជ្ជកម្ម ក្នុងល័ក្ខខ័ណ្ឌស្ថេរភាព តំលាភាព និងគ្មាន ការរើសអើង

ដោយទទួលស្គាល់ភាពចាំបាច់ក្នុងការគាំទ្រដំណើរការកែទម្រង់សេដ្ឋកិច្ចនាបច្ចុប្បន្ន ក្នុងអន្តរកាលឆ្ពោះទៅសេដ្ឋកិច្ចទីផ្សារ និងដោយទទួលស្គាល់សារៈសំខាន់នៃកិច្ចអភិវឌ្ឍន៍សង្គម ដែលត្រូវដំណើរការស្របនឹងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ព្រមទាំងការយកចិត្តទុកដាក់របស់ខ្លួនទៅលើសិទ្ធិនានាផ្នែកសង្គម

ដោយពិនិត្យឃើញភាពចាំបាច់ក្នុងការគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើនជីវភាពរស់នៅរបស់ស្រទាប់ប្រជាជនក្រីក្រ ហើយនិងប្រជារាស្ត្រដែលបាត់បង់ប្រៀប ដោយយកចិត្តទុកដាក់ពិសេសដល់លក្ខខណ្ឌរបស់ស្ត្រី

ដោយពិនិត្យឃើញសារៈសំខាន់ ដែលភាគីទាំងពីរបានយកចិត្តទុកដាក់ដល់បញ្ហាបរិស្ថាននៅគ្រប់លំដាប់ថ្នាក់ និងការគ្រប់គ្រងប្រកបដោយចីរភាពនូវធនធានធម្មជាតិ ដោយយកចិត្តទុកដាក់ដល់ទំនាក់ទំនងរវាងបរិស្ថាននិងកិច្ចអភិវឌ្ឍន៍

បានសម្រេចចុះហត្ថលេខាកិច្ចព្រមព្រៀងនេះ ហើយភាគីទាំងពីរបានចាត់តាំងតំណាងពេញសមត្ថភាពរបស់ខ្លួន ដូចខាងក្រោមនេះ ÷

## រាជរដ្ឋាភិបាលកម្ពុជា

**គាត ឈន់**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនិតិសម្បទានិងអភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ក្រុមប្រឹក្សាសហគមន៍អឺរ៉ុប :

**ហែន វ៉ាន មីអែរឡូ**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសហុល្លង់
ប្រធានក្រុមប្រឹក្សាសហគមន៍អឺរ៉ុប

**ម៉ានុយអែល ម៉ារ៉ាំង**

អនុប្រធានគណៈកម្មការនៃសហគមន៍អឺរ៉ុប

ដែលបានផ្លាស់ប្តូរសិទ្ធិប្រទានពេញលេញនិងត្រឹមត្រូវរបស់ខ្លួន
ភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចខាងក្រោម ÷

**មាត្រា១**
**គោលការណ៍គ្រឹះ**

ការគោរពគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងសេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស ដែលបានបញ្ជាក់ក្នុងនយោបាយក្នុងស្រុកនិងអន្តរជាតិរបស់សហគមន៍និងកម្ពុជា គឺជាកត្តាសំខាន់នៃកិច្ចព្រមព្រៀងនេះ ។

**មាត្រា២**
**គោលដៅ**

គោលដៅចំបងនៃកិច្ចព្រមព្រៀងនេះ គឺផ្តល់ក្របខ័ណ្ឌមួយសំរាប់ពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរក្នុងសមត្ថកិច្ចរៀងៗខ្លួន ។ គោលបំណងនៃកិច្ចសហប្រតិបត្តិការមានដូចខាងក្រោម÷

(ក) អនុវត្តទៅវិញទៅមក នូវប្រព្រឹត្តិកិច្ចនៃ " ប្រជាជាតិដែលអនុគ្រោះបំផុត " ក្នុងការផ្លាស់ប្តូរទំនិញនៅតាមបណ្តាផ្នែកដែលបានចែងយ៉ាងជាក់លាក់ក្នុងកិច្ចព្រមព្រៀងនេះ លើកលែងតែអត្ថប្រយោជន៍ដែលផ្តល់ដោយភាគីណាមួយ នៅក្នុងក្របខ័ណ្ឌនៃសហព័ន្ធពន្ធគយ តំបន់ពាណិជ្ជកម្មសេរី និងបទបញ្ញត្តិទាំងឡាយស្តីពីសកម្មភាពពាណិជ្ជកម្មតាមព្រំដែនជាមួយប្រទេសជិតខាង ឬកាតព្វកិច្ចឡាស់លាស់ ដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីផលិតផលជាមូលដ្ឋាន ។
(ខ) ជំរុញនិងបង្កើនសកម្មភាពពាណិជ្ជកម្ម និងពង្រីកយ៉ាងទៀងទាត់ នូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងភាគីទាំងពីរ ដោយផ្អែកលើគោលការណ៍ " សមភាពនិងមានផលប្រយោជន៍ទៅវិញទៅមក " ។
(គ) ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យនានា ដែលមានចំណងទាក់ទងយ៉ាងជិតស្និទ្ធនឹងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក ។
(ឃ) ចូលរួមដល់កិច្ចប្រឹងប្រែងនានារបស់កម្ពុជា ក្នុងការបង្កើនគុណភាពនិងកំរិតជីវភាពរស់នៅ របស់ស្រទាប់ប្រជាជនក្រីក្របំផុត ស្របនឹងវិធានការទាំងឡាយសំរាប់ការកសាងប្រទេសឡើងវិញ ។
(ង) លើកទឹកចិត្តដល់ការបង្កើតលទ្ធភាពការងារទាំងនៅសហគមន៍និងនៅកម្ពុជា ព្រមទាំងផ្តល់អាទិភាពខ្ពស់ដល់កម្មវិធីនិងសកម្មភាពទាំងឡាយណា ដែលអាចជះឥទ្ធិពលល្អដល់ការងារនេះ ។ ភាគីទាំងពីរ

និងផ្លាស់ប្តូរគ្នា អំពីទស្សនៈនិងពត៌មានស្តីពីគំនិតផ្តួចផ្តើមរៀងៗខ្លួន បង្កើននិងពង្រីកទំនាក់ទំនងសេដ្ឋកិច្ចទៅវិញទៅមក ព្រមទាំងបង្កើតលក្ខខ័ណ្ឌទាំងឡាយអំណោយផលដល់ការបង្កើតការងារ ។

(៦) ចាត់វិធានការចាំបាច់ដើម្បីការពារបរិស្ថាន និងគ្រប់គ្រងប្រកបដោយចិរភាព នូវធនធានធម្មជាតិ ។

## មាត្រា ៣
## កិច្ចសហប្រតិបត្តិការសំរាប់អភិវឌ្ឍន៍

សហគមន៍ទទួលស្គាល់ថា ប្រទេសកម្ពុជាត្រូវការជំនួយសំរាប់អភិវឌ្ឍន៍ ហើយត្រៀមខ្លួនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីរួមចំណែករបស់ខ្លួនក្នុងកិច្ចប្រឹងប្រែងទាំងឡាយរបស់កម្ពុជា ដើម្បីអោយប្រទេសនេះសំរេចបាននូវកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចិរភាព និងការរីកចំរើនខាងផ្នែកសង្គមកិច្ចរបស់ប្រជាជន តាមរយៈកម្មវិធី និងគំរោងការជាក់ស្តែង ស្របតាមអាទិភាពទាំងឡាយដែលបានចែងក្នុងបទបញ្ញារបស់សហគមន៍អឺរ៉ុប លេខ ៤៤៣/៩២ របស់ក្រុមប្រឹក្សា ចុះថ្ងៃទី ២៥ កុម្ភៈ ឆ្នាំ ១៩៩២ ស្តីពីជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស និងកិច្ចសហប្រតិការជាមួយប្រទេសកំពុងអភិវឌ្ឍន៍នៅទ្វីបអាមេរិកឡាទីននិងអាស៊ី ។

អនុលោមតាមបទបញ្ញាដែលបានរៀបរាប់ខាងលើ ជំនួយនឹងត្រូវផ្តោតជាសំខាន់ នៅលើក្រុមប្រជាជនក្រីក្របំផុត ។ កិច្ចសហប្រតិបត្តិការនេះនឹងផ្តល់អាទិភាពរបស់ខ្លួនទៅលើសកម្មភាព ដើម្បីកាត់បន្ថយភាពក្រីក្រ ដោយរាប់បញ្ចូលនូវរាល់សកម្មភាពសំរាប់ការបង្កើតការងារ សំរាប់ការអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន និងការលើកតំកើងតួនាទីរបស់ស្ត្រីនៅក្នុងកិច្ចអភិវឌ្ឍន៍ ។ លើសពីនេះ ភាគីទាំងពីរត្រូវលើកទឹកចិត្តដល់វិធានការចាំបាច់ៗទាំងឡាយ ដើម្បីការពារនិងប្រឆាំងនឹងជម្ងឺស៊ីដា ព្រមទាំងលើកគំនិតផ្តួចផ្តើមទាំងឡាយ ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋាននិងការអប់រំអំពីជម្ងឺអេដស៍ ព្រមទាំងពង្រឹងសមត្ថភាពផ្តល់សេវាសុខាភិបាល ។

កិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ ក៏ត្រូវយកចិត្តទុកដាក់ផងដែរ ដល់បញ្ហាគ្រឿងញៀន ជាពិសេសការបណ្តុះបណ្តាលនិងការអប់រំ ការថែទាំសុខភាព និងសមាហរណកម្មមនុស្សញៀន នៅក្នុងសង្គមវិញ ។

ភាគីទាំងពីរទទួលស្គាល់សារៈសំខាន់នៃការអភិវឌ្ឍន៍ធនធានមនុស្ស និងការអភិវឌ្ឍន៍សង្គម ព្រមទាំងការកែលំអលក្ខខ័ណ្ឌរស់នៅនិងការងារ ការអភិវឌ្ឍន៍មុខជំនាញ និងការការពារក្រុមប្រជាជនដែលទន់ខ្សោយបំផុត ។ ការអភិវឌ្ឍន៍ធនធានមនុស្សនិងការអភិវឌ្ឍន៍សង្គម គឺជាផ្នែកសំខាន់នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងកិច្ចសហប្រតិបត្តិការសំរាប់អភិវឌ្ឍន៍ ។ ក្នុងគោលបំណងនេះ ការយកចិត្តទុកដាក់ត្រូវ

ប្រមូលផ្តុំទៅលើការបណ្តុះបណ្តាល ដើម្បីឆ្លើយតបទៅនឹងតំរូវការខាងស្ថាប័ន និងទៅលើសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈ ច្បាស់លាស់ ដើម្បីបង្កើនគុណភាពពលកម្មក្នុងស្រុក ។

ដោយសហគមន៍បានចូលរួមយ៉ាងច្រើនក្នុងកម្មវិធីកំចាត់មីននៅកម្ពុជា ក្នុងការប្តេជ្ញារបស់ខ្លួនទៅអនាគត សហគមន៍នឹងបន្តការយកចិត្តទុកដាក់ទៅលើអាទិភាពដែលបានព្រមព្រៀងគ្នា ដើម្បីធានាអោយមានប្រសិទ្ធិភាពនិងមានចិរភាពរបស់ជំនួយ ។

កិច្ចសហប្រតិបត្តិការរបស់សហគមន៍នៅក្នុងក្របវិស័យ នឹងត្រូវប្រមូលផ្តុំលើអាទិភាព ដែលបានព្រមព្រៀងគ្នាទាំងសងខាង ដើម្បីធានាជំនួយនេះមានប្រសិទ្ធិភាពនិងមានចិរភាព ។ សកម្មភាពទាំងឡាយដែលត្រូវប្រកាន់យក ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសំរាប់អភិវឌ្ឍនេះ ត្រូវសមស្របទៅនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍នៃស្ថាប័នប្រើតុនវ៉ៃត ។

## មាត្រា៤
## កិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម

១. ភាគីទាំងពីរបានបញ្ជាក់ពីការប្តេជ្ញារបស់ខ្លួន ដូចខាងក្រោម÷

(ក) ចាត់វិធានការសមស្របទាំងឡាយ ដើម្បីបង្កើតលក្ខខ័ណ្ឌអំណោយផលដល់ការបង្កើនសកម្មភាពពាណិជ្ជកម្មរបស់ភាគីទាំងសងខាង ។

(ខ) កែលំអអោយបានជាអតិបរមា នូវរចនាសម្ព័ន្ធនៃការផ្លាស់ប្តូរពាណិជ្ជកម្ម ក្នុងទិសដៅបង្កើនសកម្មភាពពាណិជ្ជកម្ម អោយបានច្រើនប្រភេទ ។

(គ) ចាត់វិធានការសំដៅលុបបំបាត់ឧបសគ្គក្នុងពាណិជ្ជកម្ម និងចាត់វិធានការផ្សេងៗទៀត ដើម្បីពង្រីកតំលាភាព ជាពិសេស តាមរយៈការដកចេញរបាំងមិនមែនពន្ធដារ នៅពេលដ៏សមគួរ អនុលោមតាមកិច្ចការដែលបានប្រព្រឹត្តទៅរបស់ស្ថាប័នអន្តរជាតិដទៃទៀត ដោយការពារអោយបានត្រឹមត្រូវនូវបណ្តាទិន្នន័យផ្ទាល់ខ្លួន ។

២. ក្នុងទំនាក់ទំនងពាណិជ្ជកម្ម ភាគីទាំងពីរត្រូវយល់ព្រមផ្តល់អោយគ្នាទៅវិញទៅមក នូវប្រព្រឹត្តកិច្ចនៃប្រជាជាតិអនុគ្រោះបំផុតខាងពាណិជ្ជកម្មទំនិញ ក្នុងបណ្តាផ្នែកដែលពាក់ព័ន្ធនឹងខ្លឹមសារខាងក្រោម÷

(ក) ពន្ធគយ និងពន្ធគ្រប់ប្រភេទ រួមទាំងនិតិវិធីនៃការប្រមូលពន្ធ ។

(ខ) បទបញ្ញា ទំរង់ការនិងបែបបទ ដែលពាក់ព័ន្ធទៅនឹងការជំរះបញ្ជីពន្ធគយ ទំនិញឆ្លងកាត់ ការស្តុកទំនិញក្នុងឃ្លាំង និងការផ្ទេរទំនិញពីនាវាមួយទៅនាវាមួយ ។

(គ) ពន្ធគយនិងពន្ធផ្សេងៗក្នុងស្រុក ដោយផ្ទាល់ ឬដោយប្រយោលលើការនាំចូល ឬនាំចេញ ។

(ឃ) ទំរង់ការរដ្ឋបាលក្នុងការផ្តល់អាជ្ញាប័ណ្ណនាំចូល ឬនាំចេញ ។

៣. ក្នុងក្របខណ្ឌនៃសមត្ថកិច្ចរៀងៗខ្លួន ភាគីទាំងពីរត្រូវ÷

(ក) ក្នុងវិស័យដឹកជញ្ជូនតាមសមុទ្រ ត្រូវស្រាវជ្រាវមធ្យោបាយនានា ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការសំរាប់បង្កើនទំនាក់ទំនងទីផ្សារ លើលក្ខណៈវិនិច្ឆ័យពាណិជ្ជកម្មនិងគ្មានការរើសអើង ដោយផ្អែកលើការងារដែលបានប្រព្រឹត្តទៅដោយអង្គការអន្តរជាតិដទៃៗទៀត ។

(ខ) លើកទឹកចិត្តកិច្ចសហប្រតិបត្តិការក្នុងផ្នែកពន្ធគយ រវាងអាជ្ញាធរនៃភាគីទាំងពីរ ពិសេស ក្នុងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើអោយសាមញ្ញនិងអោយចុះសំរុងក្នុងនីតិវិធីពន្ធគយ និងជំនួយរដ្ឋបាលប្រឆាំងនឹងការគេចបន្លំពន្ធគយ ។

(គ) ផ្លាស់ប្តូរពត៌មានស្តីពីវិវដ្ឋាន ដែលអាចផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក ពិសេស ក្នុងវិស័យទេសចរណ៍ និងកិច្ចសហប្រតិបត្តិការផ្នែកស្ថិតិ ។

៤. កថាខ័ណ្ឌទី ២និងទី ៣ត្រង់ចំណុច(ក) មិនត្រូវអនុវត្តចំពោះករណីដូចខាងក្រោមឡើយ÷

(ក) អត្ថប្រយោជន៍ដែលបានផ្តល់ដោយភាគីចុះកិច្ចសន្យាណាមួយ
ដល់ប្រទេសដែលជាសមាជិកសហព័ន្ធពន្ធគយ ឬ តំបន់ពាណិជ្ជកម្មសេរី ។

(ខ) អត្ថប្រយោជន៍ដែលផ្តល់ដោយភាគីណាមួយ ដល់ប្រទេសជិតខាង ក្នុងគោលដៅសំរួលសកម្មភាពពាណិជ្ជកម្មតាមព្រំដែន ។

(គ) វិធានការនានាដែលភាគីម្ខាងប្រកាន់យក ដើម្បីបំពេញកាតព្វកិច្ចនានា ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអន្តរជាតិស្តីពីទំនិញមូលដ្ឋាន ។

៥. ប្រទេសកម្ពុជាត្រូវកែលំអលក្ខខ័ណ្ឌសំរាប់ការពារនិងអនុវត្តអោយមានប្រសិទ្ធិភាព នូវកម្មសិទ្ធិបញ្ញាឧស្សាហកម្ម និងពាណិជ្ជកម្ម ដោយអនុលោមតាមបទដ្ឋានអន្តរជាតិខ្ពស់បំផុត ។ ក្នុងន័យនេះ ប្រទេសកម្ពុជានឹងត្រូវចូលជាភាគីហត្ថលេខីនៃសន្ធិសញ្ញាអន្តរជាតិស្តីពីកម្មសិទ្ធិបញ្ញា ឧស្សាហកម្ម និង ពាណិជ្ជកម្ម ។ ជំនួយបច្ចេកទេសនឹងផ្តល់មកប្រទេសកម្ពុជា ដើម្បីមានលទ្ធភាពបំពេញកាតព្វកិច្ចដូចបានពោលខាងលើ ។

៦. ក្នុងក្របខ័ណ្ឌសមត្ថកិច្ច ច្បាប់និងបទបញ្ញត្តិរបស់ខ្លួន ភាគីទាំងពីរឯកភាពថា ត្រូវពិគ្រោះយោបល់គ្នាទៅវិញទៅមក នូវរាល់បញ្ហាឬជំលោះទាំងឡាយដែលពាក់ព័ន្ធនិងទំនាក់ទំនងពាណិជ្ជកម្ម ។

## មាត្រា ៥

## កិច្ចសហប្រតិបត្តិការក្នុងផ្នែកបរិស្ថាន

ភាគីទាំងពីរទទួលស្គាល់ថាការកែលំអការការពារបរិស្ថាន ត្រូវផ្អែកលើច្បាប់បរិស្ថានដ៏ត្រឹមត្រូវមួយ និងការអនុវត្តន៍ច្បាប់នេះអោយមានប្រសិទ្ធិភាព ព្រមទាំងបញ្ចូលការងារនេះ ទៅក្នុងគោលនយោបាយផ្សេងៗ ទៀត ។

គោលបំណងសំខាន់បំផុតនៃកិច្ចសហប្រតិបត្តិការក្នុងផ្នែកបរិស្ថាន គឺការបង្កើនលទ្ធភាពដើម្បីសំរេចនូវការរីកចំរើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងការអភិវឌ្ឍន៍សង្គម ដោយផ្តល់អាទិភាពខ្ពស់ទៅលើកិច្ចការពារបរិស្ថានធម្មជាតិ ដែលរួមមានដូចតទៅ ÷

(ក) ការរៀបចំគោលនយោបាយការពារបរិស្ថានដ៏មានប្រសិទ្ធិភាព ដែលចែងអំពីវិធានការផ្អែកច្បាប់និងធនធានគ្រប់គ្រាន់ ដើម្បីអនុវត្តវិធានការទាំងនេះ ។ ការអនុវត្តន៍ត្រឹមត្រូវនូវវិធានការទាំងឡាយនេះ មានសារៈប្រយោជន៍ចាំបាច់ ដើម្បីលុបបំបាត់សកម្មភាពកាប់ឈើខុសច្បាប់ ។ ផ្នែកនេះរួមមានការបណ្តុះបណ្តាល ការពង្រឹងសមត្ថភាព និងការផ្ទេរបច្ចេកវិទ្យាស្រមស្របខាងផ្នែកបរិដ្ឋាន ។

(ខ) កិច្ចសហប្រតិបត្តិការក្នុងកិច្ចអភិវឌ្ឍន៍ប្រភពថាមពលដែលគ្មានជាតិពុល ប្រកបដោយចីរភាព ព្រមទាំងការស្វែងរកដំណោះស្រាយនានាស្តីពីបញ្ហាជាតិពុលក្នុងតំបន់ទីក្រុង និងតំបន់ឧស្សាហកម្ម ។

(គ) បោះបង់នូវសកម្មភាពណាដែលប៉ះពាល់ដល់បរិស្ថាន ( ជាពិសេស ចំពោះតំបន់ដែលអេកូស៊ីស្តែមឆាប់ប៉ះទង្គិច) ព្រមទាំងអភិវឌ្ឍវិស័យទេសចរណ៍ ដោយធានាចំណូលប្រកបដោយចីរភាព ។

(ឃ) ការសិក្សាវាយតំលៃស្តីពីផលប៉ះពាល់ដល់បរិស្ថាន គឺជាផ្នែកសំខាន់មួយនៃរាល់គំរោងការស្តារនិងអភិវឌ្ឍន៍ នៅក្នុងគ្រប់វិស័យ គិតចាប់ពីដំណាក់ការត្រៀមរៀបចំ រហូតដល់ការអនុវត្តន៍ ។

(ង) កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និត ដើម្បីសំរេចទិសដៅនៃកិច្ចព្រមព្រៀងស្តីពីបរិស្ថាន ដែលភាគីទាំងពីរជាសមាជិក ។

(ច) ការយកចិត្តទុកដាក់ពិសេស និងគំនិតផ្តួចផ្តើមទាំងឡាយ សំរាប់ការពារព្រៃឈើដែលមានស្រាប់និងអភិវឌ្ឍប្រភពធនធានព្រៃឈើថ្មីប្រកបដោយចីរភាព ។

## មាត្រា ៦
## កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

ក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរៀងៗខ្លួន និងកំរិតខាងមធ្យោបាយហិរញ្ញវត្ថុដែលមាន ភាគីទាំងពីរបានប្ដេជ្ញាថា ត្រូវជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដែលផ្តល់ផលប្រយោជន៍អោយគ្នាទៅវិញទៅមក ។

កិច្ចសហប្រតិបត្តិការនេះនឹងត្រូវតំរង់ទិសទៅលើ ÷

(ក) កែលំអបរិស្ថានសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ដោយបង្កលក្ខណៈងាយស្រួលដល់ការទទួលចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិជ្ជាពីសហគមន៍

(ខ) សំរួលទំនាក់ទំនងរវាងភាគីសេដ្ឋកិច្ចទាំងឡាយ និងចាត់វិធានការដទៃទៀតសំរាប់ជំរុញការផ្លាស់ប្តូរពាណិជ្ជកម្ម

(គ) អនុលោមតាមច្បាប់ បទបញ្ជា និងគោលនយោបាយនានា ភាគីទាំងពីរត្រូវលើកទឹកចិត្តដល់កម្មវិធីវិនិយោគរបស់ផ្នែកសាធារណៈនិងឯកជន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច រួមទាំងកិច្ចសហប្រតិបត្តិការរវាងសហគ្រាស ការផ្ទេរបច្ចេកវិជ្ជា និងអាជ្ញាប័ណ្ណ ព្រមទាំងការម៉ៅការបន្ត ។

(ឃ) សំរួលការផ្លាស់ប្តូរព័ត៌មាននិងគំនិតផ្តួចផ្តើមនានា ជំរុញកិច្ចសហប្រតិបត្តិការស្តីពីគោលនយោបាយចំពោះសហគ្រាស ពិសេសកែលំអបរិស្ថានពាណិជ្ជកម្មនិងជំរុញទំនាក់ទំនងអោយកាន់តែជិតស្និត ។

(ង) ពង្រឹងការយល់គ្នាទៅវិញទៅមក លើបរិស្ថានសេដ្ឋកិច្ចរៀងៗខ្លួននៃភាគីទាំងពីរ ដើម្បីធានាកិច្ចសហប្រតិបត្តិការមានប្រសិទ្ធិភាព ។

នៅក្នុងវិស័យទាំងនេះ ទិសដៅសំខាន់ៗគឺ ÷

- ជួយឧបត្ថម្ភដល់ប្រទេសកម្ពុជា ក្នុងកិច្ចប្រឹងប្រែងកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន ដោយបង្កើតល័ក្ខខ័ណ្ឌទាំងឡាយសំរាប់បរិស្ថានសេដ្ឋកិច្ច និងបរិយាកាសអំណោយផលដល់សេរីភាពពាណិជ្ជកម្ម ។
- ជំរុញកិច្ចសហប្រតិបត្តិការរវាងបណ្តាផ្នែកសេដ្ឋកិច្ច ពិសេសរវាងផ្នែកឯកជនរបស់ភាគីទាំងពីរ ។
- ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន និងអនុលោមតាមច្បាប់ បទបញ្ញត្តិនិងគោលនយោបាយ ភាគីទាំងពីរត្រូវរៀបចំបរិស្ថានអនុគ្រោះដល់សកម្មភាពវិនិយោគឯកជន តាមរយៈការកែលំអលក្ខខ័ណ្ឌសំរាប់ការផ្ទេរដើមទុន និងនៅពេលសមស្រប ចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការជំរុញនិងការពារវិនិយោគ រវាងរដ្ឋជាសមាជិកនៃសហគមន៍ និងប្រទេសកម្ពុជា ។

ក្នុងផលប្រយោជន៍ទាំងសងខាង ភាគីទាំងពីរត្រូវកំណត់រួមគ្នា នូវវិស័យនិងអាទិភាព ព្រមទាំងសកម្មភាព ទាំងឡាយនៃកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ច ។

## មាត្រា ៧

## កិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម

ក្នុងស្មារតីនៃការយោគយល់ពីគ្នាទៅវិញទៅមក ភាគីទាំងពីរយល់ព្រមសហប្រតិបត្តិការក្នុងវិស័យកសិកម្ម ព្រមទាំង យកចិត្តទុកដាក់ដល់ ÷

(ក) លទ្ធភាពសំរាប់ពង្រីកវិស័យពាណិជ្ជកម្មលើផលិតផលកសិកម្ម ។

(ខ) វិធានការនានាក្នុងផ្នែកសុខភាព ភូតគាមអនាម័យនិងបរិដ្ឋានវិជ្ជា ព្រមទាំងលទ្ធផល ហើយនឹងការផ្តល់ជំនួយសំរាប់ចៀសវាងឧបសគ្គ ក្នុងពាណិជ្ជកម្ម ដោយផ្អែកតាមច្បាប់របស់ភាគីទាំងពីរ ។

(គ) លទ្ធភាពជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនសំរាប់បង្កើនប្រភេទកសិផលនាំចេញ។

## មាត្រា ៨

## វិស័យថាមពល

ភាគីទាំងពីរទទួលស្គាល់នូវសារៈសំខាន់នៃវិស័យថាមពលសំរាប់អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ព្រមទាំងរៀបចំពង្រីងកិច្ចសហប្រតិបត្តិការ តាមរយៈការពិគ្រោះយោបល់ស្តីពីគោលនយោបាយសំរាប់វិស័យថាមពល ។ កិច្ចពិភាក្សានេះត្រូវផ្អែកលើទិសដៅចំបងនៃកិច្ចអភិវឌ្ឍន៍ប្រភពថាមពលប្រកបដោយចីរភាពនៅប្រទេសកម្ពុជា ។

## មាត្រា ៩

## កិច្ចសហប្រតិបត្តិការដទៃ

កិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរអាចពង្រីកលើសកម្មភាពដទៃទៀត ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការឬសមាហរណកម្មដែលបានចុះជាមួយប្រទេសដទៃៗ ទៀតក្នុងតំបន់ ក្នុងល័ក្ខខ័ណ្ឌដែលសកម្មភាពទាំងនោះមានលក្ខណៈស្របទៅនឹងកិច្ចព្រមព្រៀងរវាងភាគី ទាំងពីរ ។

ដោយមិនបោះបង់ចោលនូវផ្នែកណាមួយ សកម្មភាពខាងក្រោមនេះត្រូវបានយកចិត្តទុកដាក់ពិសេស ÷

(ក) ជំនួយបច្ចេកទេសបរទេស ( សេវារបស់អ្នកបច្ចេកទេស ការប្រឹក្សារបស់បុគ្គលិកបច្ចេកទេសក្នុងទីផ្សារភាគខ្លះនៃការធ្វើសមាហរណកម្ម ) ។

(ខ) ការពង្រីកពាណិជ្ជកម្មរវាងតំបន់ ។

(គ) ការតម្រូវលំដាប់ក្នុងតំបន់ ព្រមទាំងគំរោងការនិងគំនិតផ្តួចផ្តើមទាំងឡាយក្នុងសមត្ថកិច្ចរបស់អង្គការនានាក្នុងតំបន់ ។

(ឃ) ការសិក្សាអំពីទំនាក់ទំនង ការដឹកជញ្ជូននិងគមនាគមន៍នៅកំរិតតំបន់ ។

## មាត្រា១០
## កិច្ចសហប្រតិបត្តិការក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

ផ្អែកតាមគោលនយោបាយរបស់ភាគីនីមួយៗ និងផលប្រយោជន៍ទៅវិញទៅមក និងក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន ភាគីទាំងពីរអាចជំរុញកិច្ចសហប្រតិបត្តិការក្នុងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ។

កិច្ចសហប្រតិបត្តិការនេះនឹងផ្តោតទៅលើ÷

- ការផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍នៅក្នុងកំរិតតំបន់ ( អឺរ៉ុប/អាស៊ីភាគអគ្នេយ៍ ) ពិសេស នៅក្នុងការអនុវត្តន៍គោលនយោបាយនិងកម្មវិធីនានា ។
- ការជំរុញទំនាក់ទំនងចិរភាពរវាងអ្នកវិទ្យាសាស្ត្ររបស់ភាគីទាំងពីរ ។
- ការពង្រីកសកម្មភាព ដើម្បីជំរុញការរកឃើញថ្មីនៅក្នុងវិស័យឧស្សាហកម្ម និងការផ្ទេរបច្ចេកវិទ្យា ។

កិច្ចសហប្រតិបត្តិការនេះអាចផ្តោតទៅលើ ÷

- ការស្រាវជ្រាវរួមគ្នាគំរោងការក្នុងតំបន់ (អឺរ៉ុប/អាស៊ីភាគអគ្នេយ៍) នៅក្នុងវិស័យដែលមានផលប្រយោជន៍រួមគ្នា ដោយមានការចូលរួមយ៉ាងសកម្មពីផ្នែកសហគ្រាស ។
- ការផ្លាស់ប្តូរអ្នកវិទ្យាសាស្ត្រ ដើម្បីជំរុញការរៀបចំគំរោងស្រាវជ្រាវ និងការបណ្តុះបណ្តាលកំរិតខ្ពស់ ។
- ការចាត់តាំងប្រជុំខាងផ្នែកវិទ្យាសាស្ត្រ ដើម្បីផ្លាស់ប្តូរព័ត៌មាននិងទំនាក់ទំនង ព្រមទាំងកំណត់ការងារដែលត្រូវស្រាវជ្រាវរួមគ្នា ។
- ការផ្សព្វផ្សាយលទ្ធផល និងការបង្កើតទំនាក់ទំនងរវាងផ្នែកសាធារណៈនិងផ្នែកឯកជន ។
- ការវាយតំលៃលើសកម្មភាពទាំងឡាយដែលពាក់ព័ន្ធ ។

គ្រឹះស្ថានឧត្តមសិក្សា មជ្ឈមណ្ឌលស្រាវជ្រាវនិងឧស្សាហកររបស់ភាគីទាំងពីរនឹងចូលរួមក្នុងកិច្ចសហប្រតិបត្តិការនេះ តាមវិធីសមស្រប ។

## មាត្រា១១
## ផលិតផលគីមីមានគ្រឿងញៀន និងការលាងប្រាក់

យោងតាមសមត្ថកិច្ចរៀងៗខ្លួន និងច្បាប់ជាធរមាន ព្រមទាំងការយកចិត្តទុកដាក់ដល់កិច្ចការដែលបានអនុវត្តដោយអង្គការអន្តរជាតិនានា ភាគីទាំងពីរបានឯកភាពធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីប្រឆាំងទប់ទល់នឹងការបំភ្លៃផលិតផលគ្រឿងញៀន ព្រមទាំងប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីប្រឆាំងនឹងការលាងប្រាក់ ។

ភាគីទាំងពីរនឹងប្រកាន់យកវិធានការពិសេស ដើម្បីប្រឆាំងនឹងការដាំដំណាំ ការផលិតនិងធ្វើអាជីវកម្មខុសច្បាប់ នូវអាភៀន និងគ្រឿងញៀន ព្រមទាំងវិធានការការពារនិងកាត់បន្ថយការញៀនជាតិពុល ។

កិច្ចសហប្រតិបត្តិការក្នុងផ្នែកនេះរួមមាន ÷
- វិធានការសំរាប់ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរូបភាពផ្សេងៗ ។
- ការផ្លាស់ប្តូរពត៌មានសំខាន់ៗ ដោយរក្សាការសំងាត់នូវទិន្នន័យផ្ទាល់ខ្លួន ។

## មាត្រា១២
## វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ភាគីទាំងពីរទទួលស្គាល់ថា ស្ថានភាពបច្ចុប្បន្ននៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ប្រទេសកម្ពុជា គឺជាការរាំងស្ទះយ៉ាងខ្លាំងសំរាប់ការវិនិយោគឯកជន និងការអភិវឌ្ឍន៍ជាទូទៅ ។ ក្នុងន័យនេះ ភាគីទាំងពីរបានឯកភាពគ្នាក្នុងការអនុវត្តន៍កម្មវិធីជាក់លាក់សំរាប់ស្តារនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ នៅប្រទេសកម្ពុជា ពិសេសក្នុងវិស័យដឹកជញ្ជូន ។

## មាត្រា១៣
## វិស័យពត៌មាន គមនាគមន៍ និងវប្បធម៌

ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន ព្រមទាំងស្របតាមគោលនយោបាយនិងផលប្រយោជន៍ទៅវិញទៅមក ភាគីទាំងពីរនឹងសហប្រតិបត្តិការគ្នានៅលើវិស័យពត៌មាន គមនាគមន៍ និងវប្បធម៌ ដើម្បីបង្កើនការយល់ដឹង

ពីគ្នាទៅវិញទៅមក និងដើម្បីពង្រឹងទំនាក់ទំនងរវាងភាគីទាំងពីរ ។ យោងតាមសារៈសំខាន់នៃអរិយធម៌ខ្មែរសម័យដើមនិងកេរ្តិ៍តំណែលខាងអរិយធម៌ ការឧបត្ថម្ភគាំទ្រនឹងអាចផ្តល់ក្នុងវិស័យដូចខាងក្រោមនេះ ដើម្បីជំរុញលើកទឹកចិត្តគំនិតផ្តួចផ្តើមថ្មីៗ ÷

(ក) ការសិក្សាត្រៀមរៀបចំនិងការផ្តល់ជំនួយបច្ចេកទេស សំរាប់ថែរក្សាបេតិកភ័ណ្ឌវប្បធម៌ ពិសេសក្នុងគោលដៅបំរើអោយវិស័យទេសចរណ៍ ។

(ខ) កិច្ចសហប្រតិបត្តិការនៅលើប្រព័ន្ធផ្តល់ពត៌មាន និងឯកសារសមោធានសោតទស្សន៍ ។

(គ) រៀបចំការផ្លាស់ប្តូរពត៌មាននានា ដើម្បីជំរុញការយល់ដឹងអំពីវប្បធម៌ ។

ភាគីទាំងពីរទទួលស្គាល់សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការក្នុងវិស័យទូរគមនាគមន៍ ពត៌មានសង្គម និងពហុសោតទស្សន៍ ។ កិច្ចសហប្រតិបត្តិការនេះអាចរួមមានការផ្លាស់ប្តូរពត៌មានស្តីពីគោលនយោបាយ បទបញ្ញត្តិរបស់ភាគីនីមួយៗក្នុងវិស័យទូរគមនាគមន៍ គមនាគមន៍ចល័ត ដោយរាប់បញ្ចូលការបង្កើតប្រព័ន្ធផ្កាយរណបសំរាប់ចរាចរណ៍ ពត៌មានសង្គម បច្ចេកវិជ្ជាពហុសោតទស្សន៍សំរាប់ទូរគមនាគមន៍ បណ្តាញនិងប្រតិបត្តិការទូរគមនាគមន៍( ឧទាហរណ៍ ការដឹកជញ្ជូន សុខាភិបាល អប់រំ និង បរិស្ថាន) ។

## មាត្រា ១៤
## និដ្ឋានផ្នែកស្ថាប័ន

១. ភាគីទាំងពីរបានឯកភាពបង្កើតគណៈកម្មការចំរុះ ដែលមានភារៈកិច្ចដូចខាងក្រោម÷

(ក) ធានាកិច្ចដំណើរការ និងការអនុវត្តន៍កិច្ចព្រមព្រៀងនេះអោយបានត្រឹមត្រូវ និងការពិភាក្សារវាងភាគីទាំងពីរ ។

(ខ) រៀបចំអនុស្សរៈ ដើម្បីជំរុញការអនុវត្តន៍ទិសដៅនានានៃកិច្ចព្រមព្រៀងនេះ ។

(គ) កំណត់អាទិភាពក្នុងបណ្តាសកម្មភាពដែលអាចធ្វើបាន ដើម្បីសំរេចទិសដៅនៃកិច្ចព្រមព្រៀង ។

២. គណៈកម្មការចំរុះនេះត្រូវបានតំណាងដែលជាមន្ត្រីជាន់ខ្ពស់របស់ភាគីទាំងពីរចូលរួម ។ គណៈកម្មការចំរុះត្រូវជួបប្រជុំសាមញ្ញជារៀងរាល់ពីរឆ្នាំ ដោយឆ្លាស់ទីកន្លែងគ្នា រវាងរាជធានីភ្នំពេញនិងទីក្រុងប្រុស្សែល តាមកាលបរិច្ឆេទដែលព្រមព្រៀងគ្នាទាំងសងខាង ។ តាមការព្រមព្រៀងគ្នា ភាគីទាំងពីរអាចកោះប្រជុំវិសាមញ្ញបាន ។

៣. គណៈកម្មការចំរុះអាចចាត់តាំងក្រុមការងារតាមផ្នែកឯកទេសនិមួយៗ ដើម្បីអនុវត្តភារកិច្ច និងដើម្បីសំរបសំរួលការរៀបចំនិងការអនុវត្តន៍កម្មវិធីនិងគំរោងការ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ ។

៤. របៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មការចំរុះ ត្រូវកំណត់ដោយការព្រមព្រៀងរវាងភាគីទាំងពីរ ។

៥. ភាគីទាំងពីរបានឯកភាពគ្នាថា គណៈកម្មការចំរុះត្រូវធានាការអនុវត្តន៍អោយបានល្អ នូវកិច្ចព្រមព្រៀងតាមផ្នែកនិងវិស័យដែលបានឯកភាពគ្នា ឬដែលនឹងអាចសំរេចរវាងសហគមន៍និងកម្ពុជា ។

៦. រចនាសម្ព័ន្ធចាត់តាំងនិងបទបញ្ជាសំរាប់ដំណើរការរបស់គណៈកម្មការចំរុះ នឹងត្រូវកំណត់ដោយការព្រមព្រៀងរវាងភាគីទាំងពីរ ។

## មាត្រា ១៥
## ការវិវត្តន៍នាអនាគត

១. ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួននិងតាមការព្រមព្រៀងគ្នា ភាគីទាំងពីរអាចពង្រីកវិសាលភាពកិច្ចព្រមព្រៀងនេះ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងអាចបំពេញបន្ថែមលើកិច្ចព្រមព្រៀងនេះ តាមរយៈកិច្ចព្រមព្រៀងតាមផ្នែកឬតាមសកម្មភាពជាក់លាក់មួយ ។

២. ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ ភាគីនិមួយៗអាចលើកសំណូមពរ ដើម្បីពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការ ដោយផ្អែកលើបទពិសោធន៍ដែលទទួលបានក្នុងពេលអនុវត្តន៍កិច្ចព្រមព្រៀង នេះ ។

## មាត្រា ១៦
## កិច្ចព្រមព្រៀងផ្សេងៗ

ដោយគ្មានប៉ះពាល់ដល់ប្រការទាំងឡាយនៃសន្ធិសញ្ញាស្តីពីការបង្កើតសហគមន៍អឺរ៉ុប កិច្ចព្រមព្រៀងនេះឬសកម្មភាពណាមួយនៃកិច្ចព្រមព្រៀងនេះ មិនអាចជះឥទ្ធិពលដល់សិទ្ធិអំណាចរបស់រដ្ឋជាសមាជិកនៃសហគមន៍អឺរ៉ុប ក្នុងក្របខ័ណ្ឌសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទ្វេភាគី ឬក្នុងការចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការសេដ្ឋកិច្ចថ្មី ជាមួយប្រទេសកម្ពុជាឡើយ ។

## មាត្រា ១៧

## ការផ្តល់ភាពងាយស្រួល

ដើម្បីសំរួលដល់កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ អាជ្ញាធរនៃប្រទេសកម្ពុជានឹងផ្តល់ការធានាព្រមទាំងការសំរបសំរួលចាំបាច់ សំរាប់កិច្ចដំណើរការរបស់មន្ត្រីនិងអ្នកឯកទេសរបស់សហគមន៍ ។ បែបបទលំអិតនៃកិច្ចព្រមព្រៀងនេះនឹងត្រូវកំណត់ដោយឡែក តាមរយៈការផ្លាស់ប្តូរលិខិតគ្នា ។

## មាត្រា ១៨

## ការអនុវត្តដែនដី

កិច្ចព្រមព្រៀងនេះត្រូវអនុវត្តម្ខាង នៅលើដែនដីដែលសន្ធិសញ្ញាបង្កើតសហគមន៍អឺរ៉ុបត្រូវអនុវត្ត និងក្នុងបណ្តាល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងសន្ធិសញ្ញានោះ ហើយម្ខាងទៀត នៅលើដែនដីនៃប្រទេសកម្ពុជា ។

## មាត្រា ១៩

## ការមិនប្រតិបត្តិកិច្ចព្រមព្រៀង

ប្រសិនបើភាគីណាមួយពិនិត្យឃើញថា ភាគីម្ខាងទៀតពុំបានបំពេញកាតព្វកិច្ចណាមួយរបស់ខ្លួនដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ភាគីនោះអាចចាត់វិធានការសមស្រប ។ ប៉ុន្តែ លើកលែងតែក្នុងករណីបន្ទាន់និងពិសេស មុនពេលចាត់វិធានការបែបនេះ ភាគីនោះត្រូវផ្តល់រាល់ព័ត៌មានពាក់ព័ន្ធចាំបាច់ទៅគណៈកម្មការចំរុះ ដើម្បី អោយគណៈកម្មការនេះស្វែងរកដំណោះស្រាយសមស្របដែលភាគីទាំងពីរអាចទទួលយកបាន ។

ក្នុងការជ្រើសវិធានការទាំងនោះ អាទិភាពត្រូវផ្តោតលើវិធានការទាំងឡាយណាដែលមានផលប៉ះពាល់តិចបំផុតដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។ តាមសំណើរបស់ភាគីម្ខាង វិធានការទាំងនេះត្រូវផ្ញើជាបន្ទាន់ទៅគណៈកម្មការចំរុះ សំរាប់ធ្វើជាមូលដ្ឋានក្នុងការពិគ្រោះយោបល់របស់ខ្លួន ។

## មាត្រា ២០

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ និងទី ២ដែលភ្ជាប់នឹងកិច្ចព្រមព្រៀងនេះគឺជាផ្នែកទាំងស្រុងនៃកិច្ចព្រមព្រៀង ។

## មាត្រា ២១
## ការចូលជាធរមាន និង ការចប់

១. កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅថ្ងៃទីមួយនៃខែ បន្ទាប់ពីពេលដែលភាគីទាំងពីរបានជូនពត៌មានអោយគ្នាទៅវិញទៅមក ស្តីពីការបំពេញចប់សព្វគ្រប់នូវបែបបទចាំបាច់របស់ខ្លួន ។

២. កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពសំរាប់រយៈពេលប្រាំឆ្នាំ ។ កិច្ចព្រមព្រៀងនេះអាចបន្តជាស្វ័យប្រវត្ត មួយឆ្នាំម្តងៗ លើកលែងតែមានភាគីណាមួយប្រកាសមិនយល់ព្រមបន្តក្នុងរយៈពេលប្រាំមួយខែមុនការផុតកំណត់កាលបរិច្ឆេទ ។

## មាត្រា ២២
## ឯកសារស្របច្បាប់

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើរៀបចំជា ២ ច្បាប់ ជាភាសាអាល្លឺម៉ង់ អង់គ្លេស ដាណឺម៉ាក អេស្ប៉ាញ៉ុល ហ្វាំងឡង់ បារាំង ក្រិច អ៊ីតាលី ហុលឡង់ ព័រទុយហ្គាល ស៊ុយអែត និងភាសាខ្មែរ ។ អត្ថបទនីមួយៗមានតម្លៃស្មើគ្នា តាមផ្លូវច្បាប់ ។